ជស/រកត/១២៩៧/២៧៣

# ព្រះរាជក្រឹត្យ

## ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

## យើង

## ព្រះបាទសម្តេចព្រះនរោត្តមសីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦ នស ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពី នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ និងពីរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្របតាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧។

## ត្រាស់បង្គាប់

## ជំពូក ទី ១

## <u>បទប្បញ្ញត្តិទូទៅ</u>

<u>មាត្រា ១</u> : មន្ត្រីរាជការស៊ីវិលទាំងអស់ត្រូវបានរៀបចំជា ក្របខ័ណ្ឌ ដែលត្រូវបែងចែកជា ឋានន្តរស័ក្តិ។

ក្របខ័ណ្ឌត្រូវចាត់ថ្នាក់ទៅតាមប្រភេទ ។

## **ជំពូក ទី ២**

## **អំពីប្រភេទ**

<u>មាត្រា ២</u> : ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលទាំងអស់ ត្រូវបែងចែកជា ៤ ប្រភេទ **ក ខ គ** និង **ឃ** ដែលកំណត់ឡើង ដោយយោងទៅតាមល័ក្ខខ័ណ្ឌអប្បបរមានៃការបណ្តុះបណ្តាល សំរាប់បញ្ចូលក្នុងក្របខ័ណ្ឌ និងកំរិតឋានានុក្រមនៃតំណែងរបស់ក្របខ័ណ្ឌ ។ ក្របខ័ណ្ឌនីមួយៗ ចាំបាច់ត្រូវចាត់បញ្ចូលទៅក្នុងប្រភេទណាមួយនៃប្រភេទទាំង ៤ តាមលក្ខន្តិកៈដោយឡែករបស់ខ្លួន ។

<u>មាត្រា ៣</u> : មន្ត្រីរាជការប្រភេទ **ក** មានមុខងារក្នុងតំណែង ដឹកនាំ អធិការកិច្ច សិក្សា និងផ្តល់យោបល់ និងមុខងារក្នុងរាល់តំណែងទទួលខុសត្រូវ ។ កំរិតអប្បបរមានៃការបណ្តុះបណ្តាល ដើម្បីអាចបញ្ចូលក្របខ័ណ្ឌក្នុងប្រភេទ **ក** គឺសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ បូក ៤ ឆ្នាំ នៃការសិក្សា ដោយមានសញ្ញាប័ត្រ ។ លក្ខន្តិកៈដោយឡែកខ្លះអាច ប្រសិនបើចាំបាច់ តម្រូវនូវកំរិតអប្បបរមានៃការបណ្តុះបណ្តាលស្មើ ឬលើសសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ បូក ៦ឆ្នាំ នៃការសិក្សាដោយមានសញ្ញាប័ត្រ ។ ក្នុងករណីនេះ ត្រូវមានផ្តល់នូវការបន្ថែមសន្ទស្សន៍បៀវត្ស ។

<u>មាត្រា ៤</u> : ប្រភេទ**ខ**មានមុខងារក្នុងការរៀបចំការងារសំរាប់អ្នកទទួលខុសត្រូវសំរេចនិងដាក់អោយអនុវត្ត ។ កំរិតអប្បបរមាដើម្បីបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទ **ខ** គឺសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ បូក ២ឆ្នាំ នៃការសិក្សាដោយមានសញ្ញាប័ត្រ ។

<u>មាត្រា ៥</u> : ប្រភេទ **គ** មានមុខងារក្នុងលេខាធិការដ្ឋាន និងមុខងារប្រតិបត្តិ ដែលតម្រូវឱ្យមានចំណេះបច្ចេកទេស ឬចំណេះធ្វើការងារ ។ កំរិតអប្បបរមាដើម្បីបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទ**គ** គឺសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ។

<u>មាត្រា ៦</u> : ប្រភេទ **ឃ** មានមុខងារក្នុងការប្រតិបត្តិ ។ ការបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទនេះ ពុំតម្រូវឱ្យមានល័ក្ខខ័ណ្ឌអំពីសញ្ញាប័ត្រឡើយ ។

<u>មាត្រា ៧</u> : កំរិតអប្បបរមានៃការបណ្តុះបណ្តាលដែលបានកំណត់ក្នុងមាត្រា ៣-៤ និង ៥ នៃព្រះរាជក្រឹត្យនេះ ត្រូវអនុវត្តចំពោះនិស្សិតទាំងឡាយណា ដែលត្រូវបានជ្រើសរើសអោយចូលមុខងារសាធារណៈ តាមការប្រលងប្រជែង ចាប់ពីថ្ងៃផ្សព្វផ្សាយព្រះរាជក្រឹត្យនេះ ។

<u>មាត្រា ៨</u> : មន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញភារកិច្ចក្នុងមុខតំណែង តាមការតែងតាំងដែលមានរួចហើយត្រូវផ្ទេរបញ្ចូលក្នុងក្របខ័ណ្ឌថ្មី ។ គណៈកម្មការអន្តរក្រសួងមួយ នឹងត្រូវបានតែងតាំងដោយអនុក្រឹត្យ ដើម្បីលើកគោលការណ៍សំរាប់ការចាត់ថ្នាក់ថ្មី ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

## **ជំពូកទី ៣**

## **អំពីក្របខ័ណ្ឌ**

មាត្រា ៩ : ក្របខ័ណ្ឌនីមួយៗ នៃមន្ត្រីរាជការ គឺជាការប្រមូលផ្តុំភ្នាក់ងារដែលមានគុណសម្បត្តិ ឬការបណ្តុះបណ្តាលដូចគ្នា ហើយដែលមានឧបនិស្ស័យកាន់តំណែងដូចគ្នា ឬប្រភេទមុខតំណែងដូចគ្នាក្នុងអាជីពរបស់ខ្លួននៅក្នុងក្រសួងណាមួយ ។

មាត្រា ១០: ក្របខ័ណ្ឌនីមួយៗត្រូវស្ថិតនៅក្រោមលក្ខន្តិកៈដោយឡែកមួយ ដែលរៀបចំដោយក្រសួងសាមី និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។ លក្ខន្តិកៈដោយឡែក ត្រូវកំណត់ឡើងដោយព្រះរាជក្រឹត្យ និងដោយមានការយល់ព្រមពីគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការបច្ចេកទេសអន្តរក្រសួងដើម្បីកែទំរង់រដ្ឋបាល និងពីក្រុមប្រឹក្សាអ្នកច្បាប់ ។

មាត្រា ១១: លក្ខន្តិកៈដោយឡែកបង្កើតក្របខ័ណ្ឌនីមួយៗ និងរៀបចំអាជីព ត្រូវស្របទៅតាមបទបញ្ញត្តិ

សហលក្ខន្តិកៈនៃមន្ត្រីរាជការស៊ីវិល និងតាមអត្ថបទថ្មីនេះ ។ លក្ខន្តិកៈដោយឡែក ត្រូវមានជាចាំបាច់នូវបទបញ្ញត្តិ ដូចតទៅ ៖

ក- ការភ្ជាប់ក្របខ័ណ្ឌក្នុងក្រសួងមួយ

ខ- ការចាត់ថ្នាក់ក្របខ័ណ្ឌទៅក្នុងប្រភេទមួយ

គ- ការកំណត់បេសកកម្មទូទៅរបស់ក្របខ័ណ្ឌ

ឃ-ការកំណត់មុខតំណែង ដែលភ្នាក់ងារក្របខ័ណ្ឌត្រូវបំពេញ

ង- ការកំណត់លក្ខណៈសម្បត្តិអប្បបរមាដើម្បីបញ្ចូលក្នុងក្របខ័ណ្ឌ និងបែបបទនៃការប្រលងប្រជែងផ្ទៃក្នុង និងការប្រលងប្រជែងចូលក្របខ័ណ្ឌរាជការ ដោយនិស្សិតសុទ្ធសាធ

ច- របបកម្មសិក្សាសាកល្បង

ឆ- ការកំណត់ឋានានុក្រមក្របខ័ណ្ឌ (បែងចែកក្របខ័ណ្ឌជាឋានន្តរស័ក្តិ និងកំណត់មុខតំណែងសម្រាប់ឋានន្តរស័ក្តិនីមួយៗ)

ជ- វិធានសម្រាប់តម្លើងថ្នាក់ និងតម្លើងឋានន្តរស័ក្តិ ។

មាត្រា ១២: អនុក្រឹត្យមួយ នឹងកំណត់ខ្លឹមសារគំរូនៃលក្ខន្តិកៈដោយឡែក និងវិធីអនុវត្តដើម្បីបង្កើតក្របខ័ណ្ឌ ។

## ជំពូកទី ៤

### អំពីឋានន្តរស័ក្តិ

មាត្រា ១៣: ឋានន្តរស័ក្តិ គឺជាលំដាប់ឋានានុក្រមនៃក្របខ័ណ្ឌ ។ ក្របខ័ណ្ឌនីមួយៗចាំបាច់ត្រូវបែងចែកជា ៣ ឋានន្តរស័ក្តិឋានានុក្រម ។ ឋានន្តរស័ក្តិនីមួយៗ ឆ្លើយតបទៅនឹងមុខតំណែង ឬសារព័ន្ធមុខតំណែងដែលមានការទទួលខុសត្រូវកាន់តែខ្ពស់ ។

មាត្រា ១៤: និស្សិតដែលមិនមែនជាមន្ត្រីរាជការ ហើយដែលត្រូវបានជ្រើសរើសតាមការប្រលងប្រជែង អោយចូលក្នុងមុខងារសាធារណៈ ចាំបាច់ត្រូវតាំងស៊ប់ក្នុងឋានន្តរស័ក្តិដំបូងនៃក្របខ័ណ្ឌ ។

មាត្រា ១៥: ជាធម្មតា ភ្នាក់ងារទាំងឡាយអាចមានឧបនិស្ស័យ សំរាប់ដំណើរការអាជីពរហូតក្នុងវិជ្ជាជីវៈរបស់ខ្លួនក្នុងឋានន្តរស័ក្តិដំបូង ដោយមានការតម្លើងថ្នាក់ជាទៀងទាត់ ទៅតាមបទបញ្ញត្តិនៃសហលក្ខន្តិកៈ និងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌរបស់ខ្លួន ។

មាត្រា ១៦: ការតម្លើងឋានន្តរស័ក្តិក្នុងឋានន្តរស័ក្តិទី ២ ទី៣ គឺសំរាប់ភ្នាក់ងារណាដែលមានគុណសម្បត្តិជាងគេ ។ ការ

តម្លើងឋានន្តរស័ក្តិនេះ ផ្អែកទៅលើភាពទំនេរនៃតំណែង ហើយប្រព្រឹត្តទៅតាមការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬតាមការទទួលបាននូវវិញ្ញាបនប័ត្រសិក្សារយៈពេលវែង នៅសាលាភូមិន្ទរដ្ឋបាល ឬសាលាអនុវត្ត ដែលទទួលស្គាល់ដោយលក្ខន្តិកៈដោយឡែក ឬតាមការប្រលងប្រជែង។ អាចត្រូវបានតម្លើងឋានន្តរស័ក្តិទី ២ នៃក្របខណ្ឌមួយ ចំពោះភ្នាក់ងារទាំងឡាយណាដែលបានឡើងដល់ថ្នាក់ទី៤ នៃឋានន្តរស័ក្តិដំបូងរួចហើយ។ អាចត្រូវបានតម្លើងទៅឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌមួយ ចំពោះភ្នាក់ងារទាំងឡាយណាដែលបានឡើងដល់ថ្នាក់ទី៤ នៃឋានន្តរស័ក្តិទី២ រួចហើយ។ ការឡើងឋានន្តរស័ក្តិទៅឋានន្តរស័ក្តិខ្ពស់ជាងមួយទៀត ផ្តល់ឧបនិស្ស័យដល់សាមីជនដើម្បីទទួលមុខតំណែង ស្របទៅតាមឋានន្តរស័ក្តិថ្មី ដូចដែលបានកំណត់ក្នុងលក្ខន្តិកៈដោយឡែក។

មាត្រា ១៧: បែបបទនៃការដាក់ចំនួនភ្នាក់ងារបច្ចុប្បន្នបញ្ចូលក្នុងឋានន្តរស័ក្តិថ្មីនៃក្របខ័ណ្ឌ និង អន្តរប្បញ្ញត្តិ ត្រូវកំណត់ដោយអនុក្រឹត្យ។

# ជំពូកទី ៥

## អំពីថ្នាក់

មាត្រា ១៨: ឋានន្តរស័ក្តិនីមួយៗ ត្រូវបានបែងចែកជាថ្នាក់ ដែលមានសន្ទស្សន៍កំណត់អំពីកំរិតលាភការ។

មាត្រា ១៩: ឋានន្តរស័ក្តិទី១ ត្រូវបានចែកចេញជា ១៤ ថ្នាក់។ ឋានន្តរស័ក្តិទី ២ ចែកចេញជា ១០ ថ្នាក់។ ឋានន្តរស័ក្តិទី ៣ ចែកចេញជា ៦ ថ្នាក់។

មាត្រា ២០: ជាធម្មតា មន្ត្រីរាជការទាំងអស់ ត្រូវបានតម្លើងថ្នាក់ក្នុង ២ឆ្នាំ ម្តង វៀរលែងក្នុងករណីដែលត្រូវបានផ្តល់អត្ថប្រយោជន៍ស្តីពីអតីតភាព ដែលជាលទ្ធផលចេញមកពីស្នាដៃពិសេស ឬបើជាការចាំបាច់ពីភាពលំបាកពីកំរិតនៃការទទួលខុសត្រូវ ឬពីលក្ខណៈស្ថិតក្នុងតំបន់ដាច់ស្រយាលនៃមុខតំណែងខ្លះ។ លក្ខន្តិកៈដោយឡែក ត្រូវកំណត់ព្រំដែនជាក់លាក់នៃមុខតំណែង ដែលអាចផ្តល់អត្ថប្រយោជន៍លើអតីតភាពថ្នាក់។

# ជំពូកទី ៦

## អវសានប្បញ្ញត្តិ

មាត្រា ២១: នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី ២ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ។

មាត្រា ២២: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយ**

**សូមឡាយព្រះហស្តលេខា ព្រះមហាក្សត្រ**

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ហត្ថលេខា** | **ហត្ថលេខា** |
| **អ៊ឹង ហួត** | **ហ៊ុន សែន** |

**បានជំរាបជូន**

**ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២**

**រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

**ហត្ថលេខា**

**ប្រាក់ សុខ**

លេខ: ២៨៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា និងត្រា**

**ណាឌី តាន់**